# របាយការណ៍វឌ្ឍនភាពគម្រោងប្រចាំឆ្នាំ ២០២២
# របស់អង្គការ អាសេដូ (RCEDO)
# ប្រចាំខេត្តឧត្តរមានជ័យ

## រយៈពេលនៃរបាយការណ៍
## ០១ ខែ មិនា ដល់ ៣០ ខែ តុលា ឆ្នាំ ២០២២

| | |
|---|---|
| **ឈ្មោះគម្រោង** | សាលាបៃតង ខេត្តឧត្តរមានជ័យ (Blue School Project -BS) |
| **គាំទ្រថវិកា** | ស្ថានទូតសាធារណរដ្ឋឆែក (Czech Republic Embassy) |
| **អង្គការអនុវត្តន៍** | អង្គការអភិវឌ្ឍន៍សហគមន៍ជនបទ និង បរិស្ថាន (អាសេដូ)<br>Rural Community and Environment Development Org (RCEDO). |
| **ចំណាយថវិកាសរុប** | US$ ១៩,៥២៧.00 |
| **រយៈពេលនៃគម្រោង** | ០១ ខែមិនា ដល់ ថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០២២(១០ ខែ) |
| **ថ្ងៃរៀបចំរបាយការណ៍** | ២៨ ខែវិច្ឆកា ឆ្នាំ ២០២២ |

## ១-ប្រវត្តិគម្រោង

ដោយសារបទពិសោធន៍កន្លងមក និងការអនុវត្តជោគជ័យរបស់អង្គការអាសេដូ (RCEDO) នូវគម្រោងសាលាបៃតង (Blue School project -BS) អង្គការមានគោលបំណងចម្លង និងពង្រីកគម្រោងនេះ ទៅកាន់តំបន់គោលដៅថ្មី នៃខេត្តឧត្តរមានជ័យ ដោយប្រើវិធីសាស្រ្តសាលាបៃតង (BS) ដែលអនុវត្តក្នុងខេត្តបន្ទាយមានជ័យ ។ គំនិតសាលាបៃតង ត្រូវបានសាកល្បងយ៉ាងហ្មត់ចត់ និងកែលម្អតតឈប់ឈរ ។ តាមរយៈគោលគំនិតនេះបានបង្ហាញថា វាជាវិធីសាស្រ្តដ៏ជោគជ័យមួយ មិនត្រឹមតែធ្វើឱ្យប្រសើរឡើងនូវកម្មវិធីទឹកស្អាត និងអនាម័យ (WASH) នៅក្នុងសាលារៀនប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងលើកកម្ពស់ការយល់ដឹងដល់កុមារអំពីវដ្តនៃទឹកទាំងមូល និងសារៈសំខាន់នៃការការពារធនធានទឹកផងដែរ ។ សាលាបៃតងមានលទ្ធភាព

ក្នុងការចម្លងធាតុសំខាន់ៗ ជាច្រើននៃគម្រោងនេះនៅក្នុងសាលារៀន ហើយវាមិនត្រឹមតែគោលដៅឪពុកម្តាយប៉ុណ្ណោះទេ ថែមទាំងកូនៗរបស់ពួកគេផងដែរ -ជាមួយនឹងឥទ្ធិពលរបស់វា។

នាថ្ងៃទី ១៥ ខែមិនា ឆ្នាំ ២០២២, អង្គការ អាសេដូ (RCEDO) បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយស្ថានទូតឆែក(Czech Republic Embassy) លើគម្រោង Blue School Project (BS) ដើម្បីអនុវត្តសាលាបឋមសិក្សាគោលដៅចំនួន ៣ គឺ សាលាបឋមសិក្សា ហ៊ុន សែនឈូក សាលាអភិវឌ្ឍន៍ និង សាលាគោកភ្លុក ក្នុងក្រុងសំរោង និង សង្កាត់កូនគ្រៀល ក្នុងខេត្តឧត្តរមានជ័យ ដែលមានរយៈពេលអនុវត្ត ១0ខែ ចាប់ពីខែ ០១ មិនា ដល់ ខែតុលា ឆ្នាំ ២០២២ ។

គម្រោងសាលាបៃតងមានគោលបំណង សាងសង់បង្គន់អនាម័យ កសាងកន្លែងលាងសម្អាតដៃ ផ្តល់ទឹកស្អាតប្រកបដោយសុវត្ថិភាព រៀបចំសួនបន្លែចម្រុះ និងការគ្រប់គ្រងសំណល់នៅក្នុងសាលាបឋមសិក្សា និង ពង្រឹងសមត្ថភាពលោកគ្រូអ្នកគ្រូ ក្នុងសាលាគោលដៅទាំង៣ នៅសង្កាត់សំរោង និងកូនក្រៀល នៃខេត្តឧត្តរមានជ័យ។ ក្នុងការអនុវត្តគម្រោងសាលាបៃតងនេះ អង្គការ អាសេដូ (RCEDO) បានសហការជាមួយមន្ទីរអប់រំ យុវជន និង កីឡា ខេត្តឧត្តរមានជ័យ (PDoEYS) ដើម្បីដឹកនាំការអនុវត្តគម្រោងនៅសាលាបឋមសិក្សាគោលដៅចំនួន ៣ គឺ បឋមសិក្សាហ៊ុន សែនឈូក អភិវឌ្ឍន៍ សាលាគោកភ្លុក ។ គម្រោងបានធ្វើការបណ្តុះបណ្តាលមានរយៈពេល ២ ថ្ងៃ ដោយលោកគ្រូបង្គោលពីអង្គការ អាសេដូ បានធ្វើបទបង្ហាញ និង ការលើកទឹកចិត្តដល់សិក្ខាកាមឱ្យបង្កើតផែនការសកម្មភាពរបស់សាលាបៃតង (Blue School) ដើម្បីបញ្ជ្រាបចូលទៅក្នុងកម្មវិធីសិក្សារបស់សាលានិមួយៗ ដូចជាផែនការស្តីពីៈ ការថែទាំបង្គន់អនាម័យ និងសំភារៈអនាម័យ ការអនុវត្តការលាងដៃ, ការគ្រប់គ្រងកាកសំណល់, ទឹកផឹកប្រកបដោយសុវត្ថិភាព, សួនបន្លែសាលារៀន និង បរិស្ថានសាលា។

## ២. លទ្ធផលរំពឹងទុកៈ

១. សាងសង់បង្គន់អនាម័យ កសាងកន្លែងលាងសម្អាតដៃ ផ្តល់ទឹកស្អាតប្រកបដោយសុវត្ថិភាព រៀបចំសួនបន្លែចម្រុះ និងការគ្រប់គ្រងសំណល់នៅក្នុងសាលាបឋមសិក្សាគោលដៅទាំង៣ ក្នុងសង្កាត់សំរោង និង កូនក្រៀល នៃខេត្តឧត្តរមានជ័យ។

២. សិក្សានុសិស្ស និងលោកគ្រូ អ្នកគ្រូចំនួន ៨៤១នាក់ (ស្រី៤០១នាក់) បានទទួលនូវចំណេះដឹង និង ចូលរួមអនុវត្តកម្មវិធីសាលាបៃតង(Blue School) យ៉ាងសកម្ម និងមានប្រសិទ្ធភាពក្នុងសាលានិមួយៗ។

៣. គ្រូបង្រៀន និងសិស្សតូចៗបានយល់ និងអនុវត្តចំណេះដឹងរបស់ពួកគេលើការអនុវត្តអនាម័យ/អនាម័យ សួនបន្លែចម្រុះ និង ការគ្រប់គ្រងកាកសំណល់នៅក្នុងសាលារបស់ពួកគេ។

**៣. តំបន់គោលដៅរបស់គម្រោង៖** សាលាគោលដៅទាំងបី គឺ សាលាបឋមសិក្សា ហ៊ុន សែនឈូក សាលាអភិវឌ្ឍន៍ និង សាលាគោកក្លុក ក្នុងក្រុងសំរោង និង សង្កាត់កូនគ្រៀល ខេត្តឧត្តរមានជ័យ។

## ៤. សកម្មភាព និង លទ្ធផលសម្រេចបានសាលាបៃតង

សកម្មភាពអនុវត្តគម្រោង Blue School នៅក្នុងសាលាបឋមសិក្សាគោលដៅទាំង ៣ នៃខេត្តឧត្តរមានជ័យបានបញ្ចប់ដោយជោគជ័យ ១០០% តាមផែនការព្រមព្រៀងជាមួយម្ចាស់ជំនួយ លើការងារបណ្តុះបណ្តាលដល់គ្រូបង្រៀន(TOT) ការងារផ្សព្វផ្សាយចំណេះដឹងដល់សិស្ស ការសាងសង់បង្គន់អនាម័យ រួមទាំងហេដ្ឋារចនាសម្ព័ន្ធបំពាក់ WASH (មានបង្គន់ សំភារះលាងដៃជាក្រុម តម្រងទឹកស្អាត) ជំនួយសម្ភារៈសម្រាប់ការគ្រប់គ្រងកាកសំណល់ ជំនួយសម្ភារៈសម្រាប់សួនច្បារសាលារៀន ។ ខាងនេះជាសកម្មភាព និង លទ្ធិផលសំរេចបាន នៃរយៈពេលគម្រោង៖

1. បានប្រជុំបង្ហាញគម្រោងកម្មវិធីសាលាបៃតងជូនដល់មន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ និង សាលាបឋមសិក្សាគោលដៅទាំង៣ ដែលមានអ្នកចូលរួមសរុបចំនួន ១២ នាក់ ស្រី ២នាក់។ គោលបំណងនៃកិច្ចប្រជុំគឺធ្វើបទបង្ហាញ និង ផ្សព្វផ្សាយពីគោលគំនិត Blue School (BS) និងវិធីសាស្រ្តបណ្តុះបណ្តាលអនាម័យ និងអនាម័យកុមារ(CHAST) និងសកម្មភាពសំខាន់ៗ ។
2. អាសេដូ បានវគ្គបណ្តុះបណ្តាលគ្រូបង្គោលរយៈពេល២ថ្ងៃ ស្តីអំពីគោលគំនិត និង ដំណើរការអនុវត្តសាលាបៃតង ក្នុងនោះមានការថែទាំរចនាសម្ព័ន្ធអនាម័យ ទឹកស្អាតសម្រាប់បរិភោគ ការលាងសម្អាតដៃ ការគ្រប់គ្រងសម្រាម និង កាកសំណល់រឹង ដល់នាយកសាលា លោកគ្រូអ្នកគ្រូ និងអ្នកពាក់ព័ន្ធ ដែលមានអ្នកចូលរួមចំនួន ៣១ នាក់ ស្រី ១៦ នាក់។ វគ្គនេះបានបង្កើតផែនការសកម្មភាពរបស់សាលាបៃតង (Blue School) ដើម្បីបញ្ជ្រាបចូលទៅក្នុងកម្មវិធីសិក្សារបស់សាលានិមួយៗ ដូចជាផែនការស្តីពីៈ ការថែទាំបង្គន់អនាម័យ និងសំភារះអនាម័យ ការអនុវត្តការលាងដៃ, ការគ្រប់គ្រងកាកសំណល់, ទឹកផឹកប្រកបដោយសុវត្ថិភាព, សួនបន្លែសាលារៀន និង បរិស្ថានសាលា។





3. អង្គការ អាសេដូ បានកសាងហេដ្ឋារចនាសម្ព័ន្ធអនាម័យ និង ទឹកស្អាតសម្រាប់បរិភោគ ដោយផ្តល់នូវធុងចម្រោះទឹក តាមសាលាបឋមសិក្សាចំនួន ៣ គឺ សាលាបឋមសិក្សា ហ៊ុន សែនឈូក សាលាអភិវឌ្ឍន៍ និង សាលាគោកក្លុក ក្នុងក្រុងសំរោង និង សង្កាត់កូនគ្រៀល ក្នុងមានសាង់ហេដ្ឋារចនាស

ម្ព័ន្ធបង្គន់ថ្មី១ និង កែសម្រួលហេដ្ឋារចនាសម្ព័ន្ធ និងជួសជុលតាមស្តង់ដា បានចំនួន ២ និង ដាក់ធុងញែកសម្រាមទាំងបីសាលា ។

 

4. បានអប់រំផ្សព្វផ្សាយពីការប្រើប្រាស់ និង ថែទាំរចនាសម្ព័ន្ធអនាម័យ ទឹកស្អាតសម្រាប់បរិភោគ ការលាងសម្អាតដៃ និង ការគ្រប់គ្រងសម្រាម និង កាកសំណល់រឹងដល់គ្រូ និង សិស្សបានចំនួន ១១៥៥ នាក់ ស្រី៤៧៨ ក្នុងសាលាគោលដៅទាំងបី គឺ សាលាបឋមសិក្សា ហ៊ុន សែនឈូក សាលាអភិវឌ្ឍន៏ និង សាលាគោកភ្លុក ក្នុងក្រុងសំរោង និង សង្កាត់កូនគ្រៀល ខេត្តឧត្តរមានជ័យ ។

  

5. បានបង្កើតនូវប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹង ដោយបានផ្តល់ធុងញែកចំនួន៣សម្រាប់ ដើម្បីកែឆ្នៃប្រើប្រាស់ឡើងវិញ សំរាប់សួនដំណាំ និង ការតែងថ្នាក់រៀន ។ល។ អង្គការបានសហការជាមួយលោកគ្រូអ្នកគ្រូ ផ្សព្វផ្សាយចំណេះដឹងសិស្សបានចំនួន ១១៥៥នាក់ ស្រី៤៧៨ ។

 

6. គាំទ្រលើសម្ភារៈអនាម័យប្រចាំត្រីមាសដល់សាលាបឋមសិក្សាគោលដៅទាំង៣ គឺ ហ៊ុន សែនឈូក សាលាអភិវឌ្ឍន៏ និង សាលាគោកភ្លុក ក្នុងនោះមានសាប៊ូលាងដៃ ប៉ោយទឹក អំបោស ស្បែកជើង ។

7. បានបង្កើតនូវសួនដាំដំណាំចំរុះ និង អនុវត្តដាំដុះផ្ទាល់ ដើម្បីលើកកំពស់អាហារូបត្ថម្ភតាមសាលារៀនគោលដៅទាំង ៣សាលាសាលាបឋមសិក្សា ហ៊ុន សែនឈូក សាលាអភិវឌ្ឍន៍ និង សាលាគោកភ្លុក និងជាលទ្ធផលសិក្សាមានសិស្សចូលរួម និង ទទួលបានបន្លែស្រស់មកផ្ទះសំរាប់បរិភោគ ។
8. បានបណ្តុះបណ្តាលវិធីសាស្រ្តធ្វើជីកំប៉ុស៍គោក និងកំប៉ុស៍ទឹក ព្រមទាំងការរៀបចំដី ទាំងបីសាលាគោលដៅ មានសិស្សចូលរួមចំនួន ១៣៣នាក់ ស្រី៤៣ នាក់ ។








9. បានរៀបចំប្រជុំប្រចាំត្រីមាសទាំង៣សាលាគោលដៅ បាន ៣ដង មានអ្នកចូលរួម៥៤នាក់ (ស្រី៤១) ក្នុងសាលានិមួយៗ ដើម្បីពិនិត្យសមក្ខភាពសំរេចបាន ធ្វើបច្ចុប្បន្នភាពផែនការអនុវត្តសកម្មភាពបន្ត និង គៀរគងធនធានសហគមន៍របស់សាលាបៃតង (Blue School) ដើម្បីបញ្ជ្រាបចូលទៅក្នុងកម្មវិធីសិក្សារបស់សាលានិមួយៗ។
10. ការចុះត្រួតពិនិត្យនិង វាយតំលៃ សកម្មភាពរបស់អ្នកម៉ៅការ សាងសង់ហេដ្ឋារចនាសម្ព័ន្ធបង្គន់ថ្មី១ និង ការអនុវត្តសកម្មភាពសាលាបៃតង ការប្រើប្រាស់ និងការថែទាំរចនាសម្ព័ន្ធអនាម័យ ការគ្រប់គ្រងសម្រាម និង កាកសំណល់រឹងចំនួន ៣ដង មានអ្នកចូលរួម ២៧នាក់ ស្រី ៤នាក់ ។ (សូមមើលឧបសម្ព័ន្ធ៖ រូបថតសកម្មភាព ខាងក្រោម)។









11. នាថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០២២, អង្គការអាសេដូ បានសហការជាមួយសាលាគោលដៅ បានរៀបចំតាំងពិព័ណ៌រូបភាពសកម្មភាពសម្រេចបានរបស់សាលាបៃតងទាំង៣គោលដៅ និងធ្វើបទបង្ហាញពីចែករំលែកចំណេះដឹង  និង បទពិសោធន៏នានាក្នុងការអនុវត្តកម្មវិធីសាលាបៃតងតាមសាលានិមួយៗ នៅសាលប្រជុំមន្ទីរអប់រំ យុវជន និងកីឡាខេត្តឧត្តរមានជ័យ ។ ក្នុងកម្មវិធីនេះយើងបានអញ្ជើញតំណាងស្ថានទូតសាធារណៈរដ្ឋឆែក អ្នកពាក់ព័ន្ធ តំណាងសហគមន៏ លោកគ្រូអ្នកគ្រូ និង បុគ្គលិកអង្គការនានា ដើម្បីចូលរួមចែករំលែក និង ទស្សនាពិព័ណ៌តាមសាលានិមួយៗ ។ កម្មវិធីនេះមានអ្នកចូលរួមសរុបចំនួន ៣៧នាក់ ។






# ៥. បញ្ហាប្រឈម

1. ការផ្ទុះនូវជម្ងឺឆ្លងជាសកល កូវីដ-១៩ ធ្វើអោយតម្លៃសំភារះឡើងថ្លៃជាងគម្រោង និងមានយឺតយ៉ាវក្នុងការអនុវត្តផែនការ សកម្មភព។
2. អាជ្ញាធរភូមិឃុំមួយចំនួនអនុវត្តគោលការណ៍ភូមិឃុំមានសុវត្ថិភាព មិនទាន់មានប្រសិទ្ធភាព
3. ជួបគ្រោះធម្មជាតិទឹកជំនន់ ក្នុងសង្កាត់គោលដៅ និងសាលាទាំង៣ ធ្វើអោយខូចសួនដំណាំ និងបរិស្ថានសាលា ។
4. ថវិកាគម្រោងសំរាប់អនុវត្តសកម្មភាព និងការគាំទ្រដល់ប្រតិបត្តិការ មានចំនួនតិចតួច

# ៦. ផែនការអនុវត្តឆ្នាំ ២០២៣

១. បន្តពង្រឹងសមត្ថភាពលោកគ្រូអ្នកគ្រូ និង គណៈកម្មការទ្រទ្រង់សាលាក្នុងការបន្តអនុវត្តផែនការសកម្មភាពរបស់សាលាបៃតង ដើម្បីបញ្ជ្រាបចូលទៅក្នុងកម្មវិធីសិក្សារបស់សាលានិមួយៗ។

២. បន្តរៀបចំប្រជុំប្រចាំត្រីមាសទាំង៣សាលាគោលដៅ និង ពង្រឹងលើសកម្មភាពបំណឹងជីវិតដល់សិស្ស។

៣. បន្តផែនការគាំទ្រគម្រោងសាលាបៃតង ជំហ៊ាន-២ ឆ្នាំ ២០២៣ ដល់សាលាគោលដៅចំនួន ៣ថ្មីទៀត និងសាលាគោលដៅចាស់ ៣ ក្នុងក្រុងសំរោង នៃខេត្តឧត្តរមានជ័យ ។

**ធ្វើនៅឧត្តរមានជ័យថ្ងៃទី ២៨ ខែ វិច្ឆកា ឆ្នាំ២០២២**

**រៀបចំដោយក្រុមការងារអង្គការ អាសេដូ**

**ហត្ថលេខាប្រធានអង្គការ**

RCEDO
Rural Community and Environment Development Organization

**សំ សេរីវឌ្ឍនា**